ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៣៩ សស.ធទឧ

# សេចក្តីជូនដំណឹងបន្ថែម
## ស្តីពី ស្ថានភាពអាកាសធាតុ និងរបាយទឹកភ្លៀងដើមរដូវវស្សា ឆ្នាំ ២០១៤

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងបន្ថែមដល់សាធារណជនឱ្យបានជ្រាបថា នៅដើមរដូវវស្សា ឆ្នាំ 2014 នេះ ពោលគឺចាប់ពីសប្តាហ៍ទី 3 នៃខែឧសភា រហូតដល់ពាក់កណ្តាលខែកក្កដា ឆ្នាំ 2014 ខ្យល់មូសុងនិរតីខ្សោយ និងជ្រលងសម្ពាធទាបខ្សោយ នឹងមានឥទ្ធិពលគ្របដណ្តប់លើព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ ការទទួលរងឥទ្ធិពលពីអាកាសធាតុបែបនេះ នឹងធ្វើឱ្យរាជធានី-ខេត្ត ក្នុងក្របខ័ណ្ឌទូទាំងប្រទេស មានស្ថានភាពដូចខាងក្រោម :

- ខេត្តព្រះវិហារ រតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ឆ្នាំង និងខេត្តកំពង់ធំ នឹងមានសីតុណ្ហភាពអតិបរមាពី 34 ទៅ 37 $^{o}C$ និងអាចមានភ្លៀងធ្លាក់ពីមធ្យមទៅបង្គួរ ។
- រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កំពង់ចាម ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប និងខេត្តឧត្តរមានជ័យ នឹងមានសីតុណ្ហភាពអតិបរមាពី 35 ទៅ 37 $^{o}C$ និងអាចមានភ្លៀងធ្លាក់ពីតិចទៅមធ្យម ហើយរបាយទឹកភ្លៀងធ្លាក់រាយប៉ាយពុំបានល្អទេ ។
- ខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តកំពត មានសីតុណ្ហភាពអតិបរមាពី 33 ទៅ 35 $^{o}C$ និងអាចមានភ្លៀងធ្លាក់ពីតិចទៅមធ្យម ហើយរបាយទឹកភ្លៀងធ្លាក់រាយប៉ាយពុំបានល្អទេ ។

យោងតាមស្ថានភាពអាកាសធាតុដូចបានព្យាករណ៍ខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងបងប្អូនប្រជាកសិករ សូមចូលរួមសហការជាមួយមន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត ដើម្បីមានវិធានការថែរក្សាទឹកទុក និងត្រូវមានការឃ្លាំមើលថ្ងៃប្រឌិតក្នុងការងារបង្កបង្កើនផលស្រូវរដូវវស្សា ។ ក្នុងន័យនេះ ការរៀបចំឱ្យមានថ្នាលសំណាបរួម នៅជិតទីតាំងដែលមានប្រភពទឹកអចិន្ត្រៃយ៍ គឺជាមធ្យោបាយជួយដល់ប្រជាកសិករដ៏ប្រសើរបំផុត ។

ទន្ទឹមនឹងនេះ សាធារណជនក៏ត្រូវបង្កើនការប្រុងប្រយ័ត្នចំពោះស្ថានភាពផ្គរ រន្ទះ ខ្យល់កន្ត្រាក់ និងជំនន់ទឹកភ្លៀង ដែលនៅតែមានឥទ្ធិពលខ្លាំង រហូតដល់ពាក់កណ្តាលខែកក្កដា ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh